កម្រង អត្ថបទ ធម៌ទេសនា

ស្តីអំពី

# “ព្រះពុទ្ធសាសនា”

ភិក្ខុ **កែវ-អ៊ុន** ឬ **សំអឿន**

“ **អភិញ្ញានសីលោ** ”

**វត្ត សម្តេចព្រះមហាឃោសានន្ទ**

“សាខាមជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរអន្តរជាតិ”

ទីក្រុងអូកឡិនដ៍ រដ្ឋកាលីហ្វ័រនីញ៉ា

សហរដ្ឋ អាមេរិក

សុក្រ៨កើតចេត្រ,ឆ្នាំម្សាញ់បញ្ចស័កព.ស.២៥៥៦; ទី២៨មេសា គ.ស.២០១៣

សូមលោកអ្នក មេត្តានឹកឈ្មោះខ្ញុំ,ហើយឧទ្ទិសកុសលឲ្យដល់ខ្ញុំផង!

# អត្ថបទធម៌ ស្តីអំពី ព្រះពុទ្ធសាសនា

សាធុសប្បុរសទាំងឡាយ! អស់លោកជាញាតិញោមដែលបានអញ្ជើញមកសមាទានសីល៥,សីល៨, តាមប្រក្រតីធម្មតាជារៀងរាល់ថ្ងៃសីលនេះឬអស់លោកអ្នកខ្លះមិនទាន់បានសមាទានសីលនៅឡើយទេ! ប៉ុន្តែអស់លោកក៏បានអញ្ជើញមកវត្តដែរ គឺសុទ្ធតែដោយសារអស់លោកអ្នកមានសទ្ធាជ្រះថ្លាជឿជាក់ក្នុងព្រះពុទ្ធសាសនាហើយ បានជាអស់លោកអញ្ជើញមកសមាទានសីលកើត,មកវត្តកើត,ហើយអញ្ជើញមកនេះទៀតសោតសុទ្ធតែប្រកបដោយចេតនាដ៏ល្អប្រសើរដោយភ្ជាប់មកជាមួយនឹងការអញ្ជើញមកនេះអស់លោកសុទ្ធតែបានចំណាយធនធានបន្តិចបន្តួចនាំជាចង្ហាន់បិណ្ឌបាត្រមកប្រគេន!ព្រះសង្ឃទៀតផង, នេះ គឺសុទ្ធតែដោយសទ្ធាជ្រះថ្លាទាំងអស់ហើយ ហើយក៏ជាទង្វើដ៏ល្អប្រសើរបំផុតព្រោះអ្វី?ព្រោះសុទ្ធតែជាអំពើល្អជាបុណ្យជាកុសលទាំងអស់។ ក៏ប៉ុន្តែខ្ញុំចង់និយាយបន្ថែម ពីលើជំនឿរបស់អស់លោកអ្នកទៅទៀតអំពី"ព្រះពុទ្ធសាសនា" ដើម្បីឲ្យអស់លោកខ្លះ ដែលនៅមិនទាន់ច្បាស់!គឺនៅស្រពិចស្រពិលនៅឡើយនោះ, ឲ្យបានយល់ច្បាស់ឡើងថែមទៀត ជាពិសេសដែលសំខាន់បំផុតនោះគឺចង់ឲ្យពួកយុវវ័យស្តាប់ស្តាប់ព្រះធម៌ ហើយធ្វើការពិចារណាដោយប្រើវិចារណញ្ញាណគឺបញ្ញាដ៏ជ្រាលជ្រៅរបស់ខ្លួនឲ្យបានច្បាស់លាស់, ឲ្យបានដឹតដល់រួចសឹមធ្វើជំនឿដោយខ្លួនឯងផងចុះអំពីព្រះពុទ្ធសាសនាថាៈតើព្រះពុទ្ធសាសនាគួរជឿឬមិនគួរជឿ? គួរកាន់ឬមិនគួរកាន់?សំនួរថាៈតើការពិចារណាអំពីព្រះពុទ្ធសាសនានេះ ពិចារណាដូចម្តេចទៅ?, គឺៈទី១- តើហេតុអ្វីបានជាអ្នកកាន់ព្រះពុទ្ធសាសនា?, ទី២- តើព្រះពុទ្ធសាសនានេះមានអត្ថន័យដូចម៉េច? ទី៣- តើព្រះពុទ្ធសាសនា ប្រដៅមនុស្សដូចម្តេច? បើគេធ្វើសំនួរ៣មាត់ប៉ុណ្ណឹង តើយើងអ្នកកាន់ព្រះពុទ្ធសាសនាគួរឆ្លើយបែបម៉េច?ការពិចារណាអំពីព្រះពុទ្ធសាសនា គឺត្រូវពិចារណាទៅតាម

ចម្លើយៈ របស់សំនួរទាំង៣មាត់ហ្នឹង! ដែលខ្ញុំនឹងជំរាបជូន ដូចតទៅៈ សំនួរទី១ដែលគេសួរថាៈតើហេតុអ្វីបានជាអ្នកកាន់ព្រះពុទ្ធសាសនា? សំនួរនេះសុំកុំឆ្លើយថាៈ“ខ្ញុំមិនដឹងហេតុផលច្បាស់លាស់ដែរតែដោយឃើញជីដូនជីតាមាតាបិតារបស់ខ្ញុំកាន់ព្រះពុទ្ធសាសនាហើយខ្ញុំក៏កាន់ដែរទៅ!”កុំឆ្លើយបែបហ្នឹងមិនល្អទេមិនប្រសើរទេ!។ សំនួរទី១នេះគួរឆ្លើយថាៈ បានជាខ្ញុំកាន់ព្រះពុទ្ធសាសនាពីព្រោះព្រះពុទ្ធដែលជា“មេ” អ្នកដឹកនាំព្រះពុទ្ធសាសនាព្រះអង្គជាមនុស្ស ដូចខ្ញុំដែរប៉ុន្តែព្រះអង្គជាមនុស្សប្រសើរវិសេសខ្ពង់ខ្ពស់ប្លែកមហាអស្ចារ្យផ្សេងពីមនុស្ស,ទេវតាឥន្ទព្រហ្មឆ្ងាយណាស់ព្រះអង្គជាអ្នកត្រាស់ដឹងនូវព្រះសព្វញ្ញុតញ្ញាណ បើឆ្លើយឲ្យខ្លីត្រឹមប៉ុណ្ណឹង។ ព្រះសព្វញ្ញុតញ្ញាណគឺជាព្រះបញ្ញាញាណដែលព្រះពុទ្ធអង្គទ្រង់ជ្រាបដឹងអ្វីៗ សព្វគ្រប់ទាំងអស់! ឥតមានសល់ចន្លោះ,ជាញាណដ៏ប្រសើរបំផុតគឺព្រះអង្គអាចជ្រាបដឹងនូវរឿងពីអតីតកាលដែលកន្លងយូរលង់ណាស់រាប់ជាតិទៅហើយក្តីរហូតមកដល់រឿងបច្ចុប្បន្នដូចជាដឹងថាៈ កាលពីជំនាន់ព្រះពុទ្ធអង្គនោះកន្លងទៅប៉ុណ្ណេះជាតិហើយ,ខ្លួនអ្នកធ្លាប់បានកើតនៅទីនោះ,ក្នុងត្រកូលបែបនោះ,មានឈ្មោះដូច្នោះមានអាយុប៉ុណ្ណោះទើបស្លាប់ដូច្នេះជាដើមនិងដឹងរឿងរ៉ាវទៅអនាគតដ៏វែងឆ្ងាយទៅមុខទៀតឥតមានទើសទាក់ព្រះអង្គជាមហាអ្នកប្រាជ្ញដ៏កំពូល!ប្រសើរអស្ចារ្យបំផុត!លើសអ្នកប្រាជ្ញទាំងឡាយក្នុងត្រៃលោកឥតមានអ្នកប្រាជ្ញណាមួយត្រឹមស្មើនឹងព្រះអង្គឡើយ។ សូមឲ្យអស់លោកអ្នកសប្បុរសទាំងឡាយ ពិចារណាមើលថាៈផែនដីយើងនេះកើតមានឡើងមិនដឹងជាប៉ុន្មានលានឆ្នាំមកហើយទេហើយតើមានមនុស្សប៉ុន្មាននាក់ដែលចេះពោល “ពាក្យពិតសច្ចៈ”ដូចព្រះអង្គដែរ ឬទេ?(ពាក្យពិតសច្ចៈខ្ញុំនឹងពោលនៅខាងមុខ)សូមលោកអ្នកពិចារណាមើលតែកុំពិចារណាទៅតាមនិយម គឺត្រូវពិចារណាទៅតាមផ្លូវ“បញ្ញា” តាមហេតុផលសច្ចៈពិតៗថាតើមានដែរឬទេ?ឆ្លើយគឺមានតែ“ព្រះពុទ្ធ

មួយព្រះអង្គគត់!នែ!មានសេចក្តីអស្ចារ្យយ៉ាងហ្នឹង!បានជាខ្ញុំកាន់ព្រះពុទ្ធសាសនា!។ សំនួរទី២- ប្រសិនបើមានគេធ្វើសំនួរថាៈ តើព្រះពុទ្ធសានាមានអត្ថន័យដូចម្តេច?សំនួរទី២នេះយើងគួរឆ្លើយថាៈព្រះពុទ្ធសាសនាមានន័យថា “ជាដំបូន្មាន-ជាពាក្យប្រៀនប្រដៅ ដ៏ល្អប្រសើររបស់ព្រះពុទ្ធ”(ពុទ្ធប្បញ្ញត្តនិងពុទ្ធានុញ្ញាត)។ ព្រះដំបូន្មានប្រៀនប្រដៅនេះឯងហៅថា “ព្រះធម៌”ៗ មានដល់ទៅ៨ម៉ឺន៤ពាន់ព្រះធម្មក្ខ័ន្ធ ឬ៨ម៉ឺន៤ពាន់ន័យ! ដូច្នេះក៏បាន, ព្រះធម៌គឺព្រះពុទ្ធទ្រង់ស្វែងរកឃើញ, ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯងផ្ទាល់ ជាសច្ចៈធម៌,សច្ចៈធម៌នេះមានសច្ចភាពណាស់!មាន៤ប្រការ,នេះក៏ជាចម្លើយឆ្លើយតបទៅនឹងសំនួរដែលសួរពីខាងដើមនោះហើយ! ដែលថា“ពាក្យពិតសច្ចៈ”ដូចម្តេចនោះ!? ឥឡូវឆ្លើយថាមាន៤ប្រការនេះឯង!។ ធម៌សច្ចៈទី១- ទុក្ខអរិយសច្ចៈ ប្រែ,សេចក្តីទុក្ខមានពិតប្រាកដ!ធម៌សច្ចៈទី២-ទុក្ខសមុទយអរិយសច្ចៈ ប្រែ-ហេតុដែលនាំឲ្យមានទុក្ខឬឲ្យកើតទុក្ខមានពិតប្រាកដ។ ធម៌សច្ចៈទី៣-ទុក្ខនិរោធអរិយសច្ចៈ ប្រែ- សេចក្តីរំលត់ទុក្ខ,មានពិតប្រាកដ! ។ ធម៌សច្ចៈទី៤-មគ្គអរិយសច្ចៈ ប្រែ- មាគ៌ា, ផ្លូវប្រតិបត្តិ, ដើម្បីរំលត់ទុក្ខមានពិតប្រាកដ។នេះជាធម៌ដែលព្រះសម្ពុទ្ធទ្រង់បានត្រាស់ដឹងដោយព្រះសព្វញ្ញុតញ្ញាណរបស់ព្រះអង្គផ្ទាល់ពុំមែនជាធម៌ដែលព្រះអង្គបានដឹងបានស្តាប់បានឮពីបុរស-បុគ្គលណាមួយឡើយ!។ សច្ចធម៌នេះបើពោលតាមភាសាពុទ្ធសាសន៍ឲ្យពិរោះជាងនេះទៀត,ហៅថា“ព្រះពុទ្ធ-វចនៈ”ព្រះពុទ្ធវចនៈនេះឯង ក៏គឺព្រះត្រៃបិដក,មាន៣គម្ពីរគឺៈគម្ពីរព្រះវិន័យ១, គម្ពីរសុត្តន្តៈ១, និងគម្ពីរអភិធម្ម១។ គម្ពីរព្រះត្រៃបិដកនេះជាសច្ចធម៌ជាធម៌មានហេតុមានផលច្បាស់លាស់ណាស់! ពុំមែនជាធម៌ព្រាវស្មាននោះឡើយ!, ជាធម៌ដែលមិនមានអ្នកប្រាជ្ញឬ“មេ”សាសនាណាមួយនៅលើពិភពលោកនេះអាចកែប្រែថា“មិនពិតសច្ចៈ”វិញនោះបានឡើយ។ដើម្បីជាភ័ស្តុតាងសូមស្តាប់ព្រះពុទ្ធដីកាបញ្ជាក់ច្បាស់ថាៈ

“បើហេតុមាន ទើបផលមាន”!“ បើហេតុល្អ ផលក៏ល្អ,បើហេតុអាក្រក់ ផលក៏អាក្រក់។សច្ចធម៌នេះសូមស្តាប់មួយបែបទៀតៈទី១-បើនេះមាន នុ៎ះក៏មាន,បាលីៈឥមស្មឹ សតិ ឥទំ ហោតិ។២-បើនេះមិនមាន នុ៎ះក៏មិន-មាន,បាលីៈឥមស្មឹ អសតិ ឥទំ ន ហោតិ។ទី៣-បើនេះកើតឡើង នុ៎ះក៏កើតឡើង = ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ។៤-បើនេះរលត់ នុ៎ះក៏រលត់ បាលីថាៈឥមស្ស និរោធា ឥទំ និរុជ្ឈតិ។ នេះ! ជាសច្ចធម៌ជាធម៌ដែលមានហេតុមានផលច្បាស់លាស់ គឺវាច្បាស់ថែសអញ្ចឹង! រួចពាក្យពិតសច្ចៈបែបហ្នឹង!ក្រៅពីព្រះពុទ្ធបើមានលោកណាដែលចេះពោលដែរឬទេ ?សូមពិចារណាដោយសុភវិនិច្ឆ័យទៅមើល,រីឯព្រះធម៌នេះនឹងហៅថា“បដិច្ចសមុប្បាទធម៌” ឬ “បច្ចយាការវិភង្គ” ដូច្នេះក៏បាន។ ធម៌មានហេតុផល! បើនិយាយជាពាក្យខ្មែរយើងសុទ្ធសាធ!ឲ្យងាយយល់ជាងនេះគឺៈប្តីនិងប្រពន្ធអង្គុយទល់មុខគ្នានៅតុបាយ១ជាមួយគ្នា,ដែលមានបាយ១ចាន,ម្ហូប១ចាន,បើប្តីបរិភោគបាយប្តីនឹងឆ្អែត,បើប្រពន្ធបរិភោគប្រពន្ធនឹងឆ្អែត,មិនអាចប្តីបរិភោគហើយឆ្អែតដល់ប្រពន្ធផងបានទេ,នែ!នេះជាធម៌មានហេតុផលវាច្បាស់អញ្ចឹង! គឺអ្នកណាបរិភោគអ្នកនោះនឹងឆ្អែត, ព្រោះការបរិភោគជាហេតុ ឯឆ្អែត វាជាផល!។ កិច្ចទាំងនេះនិយាយជាសារុបឡើងវិញថា“ទង្វើអ្វីៗគ្រប់យ៉ាងល្អឬអាក្រក់ជាបុណ្យឬជាបាប,ពុំអាចនរណាមួយធ្វើឲ្យអ្នកណាម្នាក់ទៀតបានទេឯផលល្អឬអាក្រក់ជាសុខនិងជាទុក្ខក៏ពុំអាចនរណាមួយ ទទួលជំនួសនរណាម្នាក់ទៀតបានដែរ!”។ នែ! ដោយព្រះធម៌ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធមានហេតុមានផលច្បាស់លាស់បែបនេះ ទើបានជាខ្ញុំកាន់ព្រះពុទ្ធសាសនា!៕ (ចប់ចម្លើយសំនួរទី២)។ សំនួរទី៣ បើគេសួរថាៈតើព្រះពុទ្ធ! ឬព្រះពុទ្ធសាសនាប្រដៅមនុស្សថាម៉េច ? គួរឆ្លើយថាៈពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធហៅថា “ព្រះធម៌”ដែលព្រះអង្គទ្រង់សំដែងទូន្មានមនុស្ស,ទេវតា,ឥន្ទ,ព្រហ្ម,នោះ មានដល់ទៅ៨ម៉ឺន៤ពាន់ន័យឬ

(ធម្មក្ខន្ធ)ឯណោះ,មានច្រើនណាស់!ប៉ុន្តែបើរួមឲ្យខ្លីហើយខ្លឹមមកនៅ
ត្រឹមតែ៣ព្រះឱស្នប្ញ៣ម៉ាត់ប៉ុណ្ណោះ។ទី១-សព្វបាបស្ស អករណំ មិន
ធ្វើអំពើបាបអាក្រក់គ្រប់យ៉ាងគ្រប់ៗគ្នា!។ ទី២- កុសលស្សូបសម្បទា
ខំធ្វើបុណ្យឬអំពើល្អឲ្យបានច្រើនគ្រប់ៗគ្នា។ ទី៣-សចិត្តបរិយោទបនំ
ខំសំអាតចិត្តរបស់ខ្លួនឲ្យបានស្អាតផូរផង់គ្រប់ៗគ្នា ឯតំ ពុទ្ធានសាសនំ
ទាំង៣ម៉ាត់នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ។ ព្រះពុទ្ធឬព្រះពុទ្ធ
សាសនាប្រដៅមនុស្សដូច្នេះឯង!!។សាធុ!សប្បុរសទាំងឡាយ!យើង
ជាមនុស្សទាំងអស់គ្នា នៅលើដុំពិភពលោកនេះទាំងមូល បើយើងប្រើ
វិចារណញ្ញាណគឺបញ្ញាដ៏ជ្រាលជ្រៅរិះគិតពិចារណាដោយសុភវិនិច្ឆ័យ
ទៅតាមហេតុផលតាមសភាវៈពិតៗទៅ យើងនឹងឃើញច្បាស់ថាខ្លួន
យើងដែលបានកើតមកជាមនុស្សនៅក្នុងយុគសម័យនេះនៅសតវត្សរ៍
នេះក្នុងភទ្ទកប្បគឺផែនដីដ៏ចំរើននេះដែលមាន អច្ឆរិយបុរស ដ៏ឧត្តមប្រ
សើរខ្ពង់ខ្ពស់ជាអ្នកប្រាជ្ញដ៏កំពូលផុតគេក្នុងត្រៃលោកបានយោនយកកំ
ណើតមកកើតដល់ទៅ៥ព្រះអង្គគឺព្រះពុទ្ធបានត្រាស់ដឹង៥ព្រះអង្គនៅ
ក្នុងភទ្ទក័ប្បនេះ រួចខ្លួនយើងទាំងអស់គ្នា ដែលបានកើតក្នុង ភទ្ទកប្ប៉
ហ្នឹង!ឈ្មោះថាហៅចំជាមានភព្វ័សំណាងខ្ពង់ខ្ពស់ណាស់!ពីព្រោះព្រះ
ពុទ្ធមួយព្រះអង្គៗ កាលណាត្រាស់ដឹងឡើងសុទ្ធតែនាំមកនូវសេចក្តី
សុខសន្តិភាព មកផ្តល់ឲ្យដល់មនុស្សលោកទូទៅទាំងអស់, រួចកប្ប៉ គឺ
ផែនដីណាដែលព្រះពុទ្ធបានត្រាស់ដឹងហើយបើព្រះពុទ្ធអង្គនោះនិព្វាន
ទៅ កប្ប៉័គឺផែនដីនោះក៏ត្រូវសាបសូន្យទៅតាមអាយុកាលនៃសាសនា
របស់ព្រះអង្គនោះៗផងដែរ។ប៉ុន្តែនៅភទ្ទកប្ប៉ដែលយើងកំពុងរស់នៅ
សព្វថ្ងៃហ្នឹងមានព្រះពុទ្ធ៤ព្រះអង្គបានត្រាស់ដឹងរួចហើយមកត្រឹមព្រះ
ពុទ្ធសមណៈគោតមយើងហ្នឹង! រួចនៅមានព្រះពុទ្ធព្រះសិអារ្យមេត្រីយ៍
ត្រាស់១ព្រះអង្គទៀតជាគម្រប់៥ព្រះអង្គ,តែមិនដឹងជានៅប៉ុន្មានម៉ឺនឆ្នាំ
ទៀត,ទើបព្រះសិអារ្យមេត្រីយ៍ស្តេចយាងមកត្រាស់?ព្រះសិអារ្យមេត្រី

ក្នុងគម្ពីរចែងថាព្រះអង្គមានព្រះជន្ម៨ម៉ឺនឆ្នាំ, រួចលុះក្រោយពី៨ម៉ឺនឆ្នាំ ដែលព្រះអង្គបរិនិព្វានទៅហើយនោះមិនដឹងជាសាសនារបស់ព្រះអង្គ ស្ថិតនៅអស់រយៈកាលប៉ុន្មានឆ្នាំតទៅទៀត?លុះដល់អស់ពីសាសនា របស់ព្រះអង្គទៅទើបភទ្ទកប្បគឺផែនដីដែលយើងកំពុងរស់នៅសព្វថ្ងៃ នេះសាបសូន្យៗរួចទំរាំមានផែនដីថ្មីមួយទៀតដុះឡើងហើយទំរាំមាន ព្រះពុទ្ធបានត្រាស់ដឹងទៀតនោះ នោះមានរយៈពេលយូរណាស់!យូរ មិនដឹងជាប៉ុន្មានអសង្ខេយ្យឆ្នាំតទៅទៀតដូចមានព្រះពុទ្ធដីកាចែងថា

កិច្ឆោ មនុស្សប្បដិលាភោ   កិច្ឆំ   មច្ចាន   ជីវិតំ
កិច្ឆំ   សទ្ធម្មស្សវនំ         កិច្ឆោ ពុទ្ធានមុប្បាទោ

ប្រែៈការបានកើតអត្តភាពមកជាមនុស្សនេះជាការក្រណាស់,ការរស់ នៅរបស់សត្វទាំងឡាយក៏ជាការក្រណាស់,លំបាកណាស់, ការបាន ស្តាប់ធម៌របស់សប្បុរសក៏ជាការក្រណាស់ដែរ,ការបានត្រាស់ដឹងនៃ ព្រះពុទ្ធគ្រប់ព្រះអង្គនោះ រឹតតែជាមហាក្របំផុតណាស់ទៅទៀត!ៗ ចំណុចទាំងនេះយើងឃើញច្បាស់ហើយថាសុទ្ធតែជាសភាវៈដ៏កម្រ ក្រក្រៃណាស់,ក្រទាំងអស់!រួចបើក្រយ៉ាងហ្នឹងហើយ, យើងបានមក កើតទាន់នឹងសាសនារបស់ព្រះអង្គហើយៗបែរជាមានមនុស្សខ្លះធ្វើ ជីវិតរបស់ខ្លួនឲ្យស្ថិតនៅឆ្ងាយពីព្រះពុទ្ធ,ធ្វើជីវិតរបស់ខ្លួនឲ្យស្ថិតនៅ ឆ្ងាយពីធម៌របស់ព្រះពុទ្ធទៅវិញនោះហើយដែលមុខគួរឲ្យនឹកស្តាយ, គួរឲ្យស្តាយជាទីបំផុតនោះ!ស្តាយហួសនិស្ស័យនឹងពិពណ៌នា,ព្រោះ អ្វី?ព្រោះថាមនុស្សដែលបានកើតមកជាមនុស្សពេញណែន នៅលើ ដុំពិភពលោកទាំងមូលនេះសព្វថ្ងៃហ្នឹង! គឺកើតឡើងដោយសារគុណ បុណ្យ"ព្រះធម៌"ដែលមានសីល៥ជាបច្ច័យនេះជាពូជទើបកើតមកជា មនុស្សបាន!,នេះនិយាយតាមសច្ចៈធម៌គឺពិតជាអញ្ចឹង!រួចប្រសិនបើ មានលោកណា?ពោលថាមនុស្សកើតមកពីអ្វីផ្សេងក្រៅពីនេះទៅវិញ នោះ នោះជាការមិនពិតទេ!ៗត្រង់នេះមានជាសំនួរថាៈចុះពូជគឺសីល

៥នេះតើមាននៅឯណា ?ចម្លើយថាៈពូជគឺសីល៥នេះព្រះសង្ឃសាវ័ក
របស់ព្រះពុទ្ធលោកអ្នកថែរក្សាទុក,ព្រះសង្ឃនេះនឹងហៅថាស្រែបុណ្យ
ក៏បាន,គឺយើងត្រូវទៅសុំផ្សាំពូជសីល៥នេះពីព្រះសង្ឃ,កាលណាព្រះ
សង្ឃលោកផ្តល់ពូជនេះឲ្យមកយើងហើយ, យើងរាល់រូបម្នាក់ៗទទួល
យកបានមកហើយ,ត្រូវថែរក្សាដោយខ្លួនឯង, ថែបំប៉នដាក់ជីរស្រោច
ទឹកយ៉ាងណាដោយខ្លួនឯងផ្ទាល់,បើយើងថែរក្សាបានល្អផលក៏បានល្អ
ដែរ។ប្រសិនបើយើងយកពូជនេះបានមកហើយមិនថែទាំរក្សាឲ្យល្អទេ
ពូជនោះក៏ឲ្យផលមិនបានល្អដែរ, ជួនកាលក៏វាអាចស្វិតស្រពោនស្លាប់
ទៅវិញក៏មាន! ប្រសិនបើយើងមិនបានថែរក្សាឲ្យបានល្អទេនោះ។ រីឯ
ការសមាទានសីល៥នេះមិនមានលំបាករក្សាឡើយ, គឺគ្រាន់តែសិក្សា
សិក្ខាបទ៥ឲ្យចេះចាំ! រួចចេះតម, ចេះវៀរ និងមានចេតនាស្ម័គ្រស្មោះ,
តាំងចិត្តសមាទានពីសំណាក់ភិក្ខុឬសាមណេរទៅបានហើយ!មិនមាន
ខាតបង់អ្វីច្រើនឡើយ, ហើយមិនមានរើសវ័យទេ មិនថាចាស់ថាក្មេង,
ប្រុស,ស្រី,អ្នកមាន, អ្នកក្រ,មានបណ្តាសក្តិ, អត់បណ្តាសក្តិ ឬក៏ស្តេច,
សេដ្ឋី,គហបតី, ពាណិជករ,កម្មករ, កសិករ, អ្វីទាំងអស់!ទាំងមិនរើស
ជាតិណា,សាសន៍ណា,នគរឬទ្វីបណាទេ, គឺរក្សាបានទាំងអស់គ្នា!ឲ្យ
តែមានឆន្ទៈជ្រះថ្លាក្នុងការរក្សាសមាទានរួចប្រសិនបើបានរក្សាពីក្មេង
ផងនោះ នោះរឹតតែប្រសើរណាស់ទៅទៀត!វាជាគំរូដ៏ល្អបំផុត!។បាន
ជាថាសមាទានសីលពីក្មេងប្រសើរនោះពីព្រោះមនុស្សយើងទាំងអស់
គ្នាស្លាប់មិនថាចាស់ឬក្មេងទេ!ពីព្រោះស្លាប់វាជាប់មកជាមួយជីវិតតាំង
ពីថ្ងៃកើតមកម្ល៉េះ!។ រួចបើស្លាប់ទៅវិញដោយមិនមានធម៌គឺសីលស្ថិត
នៅក្នុងខ្លួនគឺក្នុងចិត្តវិញ្ញាណផងទេ!  នោះនឹងមិនបានទៅកើតនៅក្នុង
ស្ថានសួគ៌សុគតិភពឡើយ!។ បើនិយាយឲ្យងាយស្តាប់បំផុតទៅទៀត
នោះគឺថាកូនក្មេងសិស្សសាលាក៏អាចរក្សាសីលបានដែរ,រួចប្រសិនបើ
សិស្សសាលាណាៗនោះរក្សាសីល៥បានល្អទាំងអស់គ្នានោះ រឹតតែជា

ប្រសើរបំផុតណាស់ទៅទៀតគឺសាលានោះនឹងបានទៅជា"ថ្នាលឬជាមជ្ឈមណ្ឌលនៃចរិយាធម៌,សុជីវធម៌,សីលធម៌,ដ៏ល្អប្រសើរបំផុត, រួចឯសិស្សក្នុងសាលាមិនមានព្រួយពីរឿងបាត់បង់សម្ភារៈអ្វីៗសោះឡើយពីព្រោះសិស្សទាំងអស់!បានរក្សាសីល៥ល្អគ្រង់គ្នាហើយ។ លើសពីនេះទៀត សិស្សទាំងអស់ទៅអនាគតនឹងបានជាពលរដ្ឋដ៏ល្អប្រសើររបស់ប្រទេសជាតិ, រួចប្រសិនបើបានក្លាយទៅជាអ្នកដឹកនាំប្រទេសទៀតនោះ,ប្រទេសនោះនឹងមានយុត្តិធម៌ប្រកបដោយសន្តិភាពសម្បូរសប្បាយថ្កុំថ្កើងរុងរឿងប្រសើរបំផុតយ៉ាងពិតប្រាកដ!។ រួចប្រសិនបើសិស្សទាំងអស់នៃសាលាទាំងអស់នៅលើដុំពិភពលោកទាំងមូលហ្នឹងរក្សាសីល៥បានល្អដូចគ្នា,ទាំងអស់ទាំងពិភពលោកទាំងមូលនេះទៅទៀតផងនោះ, នោះពិភពលោកទាំងមូលហ្នឹងនឹងមានសន្តិភាពពិតៗយ៉ាងពិតប្រាកដ!!។ ពីព្រោះសីល៥ជា"រូបមន្ត"នៃ"សន្តិភាព" ពិតៗប្រសិនបើមនុស្សទាំងអស់គ្នាទូទៅនៅលើដុំពិភពលោកនេះទាំងមូលប្រព្រឹត្តកាន់តាមសីល៥នេះបានល្អគ្រប់ៗគ្នា!ទាំងអស់គ្នា! ។ នេះជាសច្ចៈធម៌ជាធម៌ពិតគឺវាពិតជាអញ្ចឹង។ជាបន្តទៅនេះខ្ញុំធ្វើអត្ថាធិប្បាយអំពី"សច្ចៈធម៌"៤ប្រការរបស់ព្រះពុទ្ធ ពីខាងដើមនោះ ឲ្យមានសេចក្តីពិស្តារបន្តិចៗដូចតទៅៈ <u>សច្ចធម៌ទី១-ទុក្ខអរិយសច្ចៈ</u> ប្រែៈសេចក្តីទុក្ខមានពិតប្រាកដ! ព្រះពុទ្ធទ្រង់ជ្រាបច្បាស់ណាស់ថាៈ លោកសន្និវាសនេះឬសង្សារលោកនេះសុទ្ធតែស្ថិតនៅក្នុងភាពមិនទៀងទាត់,មិននឹងន,មិនគ្រប់គ្រាន់,មិនមានសារៈទេ,វាពោរពេញទៅដោយទុក្ខគ្រប់ជំពូកគឺៈ១-ជាតិទុក្ខ ទុក្ខព្រោះការកើត!មនុស្សសត្វតែកើតមកហើយ,គឺមានសេចក្តីទុក្ខជាប់តាមមកជាមួយរួចស្រេចទៅហើយគឺកើតមកស្រែកង៉ាជាសញ្ញាតែម្តង!។ ២-ជរាទុក្ខទុក្ខព្រោះការចាស់គ្រាំគ្រា,ប្រែប្រួលមិនទៀងទាត់។ ៣-ព្យាធិទុក្ខ ទុក្ខព្រោះតែជម្ងឺដម្កាត់ផ្សេងៗបៀតបៀន។ ៤-អប្បិយេហិ សម្បយោគទុក្ខ ទុក្ខព្រោះជួបប្រទះនូវសត្វ-សង្ខារដែល

មិនជាទីស្រឡាញ់ពេញចិត្ត។ ៥-បិយេហិ វិប្បយោគទុក្ខ ទុក្ខព្រោះការព្រាត់ប្រាស់សត្វ-សង្ខារដែលជាទីស្រឡាញ់ពេញចិត្ត។ ៦-យម្បិច្ឆំ នលភតិ តម្បិទុក្ខ ទុក្ខព្រោះចង់បានអ្វីហើយ,មិនបានសម្រេចតាមសេចក្តីប្រាថ្នា។៧-សង្ខិត្តេន បញ្ចុប្បាទានក្ខន្ធាទុក្ខានិយាយសង្ខេបថាសង្ខារទាំងអស់ដែលកើតឡើងហើយតែងតែវិនាសទៅវិញ,ការវិនាសនោះឯងជាតួនៃសេចក្តីទុក្ខ។៨-ទីបំផុត មរណទុក្ខ,ទុក្ខព្រោះសេចក្តីស្លាប់អ្វីៗទាំងអស់សុទ្ធតែទុក្ខទុក្ខទល់គ្នានឹងស្លាប់ទើបចប់,តែចប់តែក្នុងអត្តភាពនេះទេ!នេះឯងដែលថាពោរពេញដោយសេចក្តីទុក្ខនោះគឺសុទ្ធតែទុក្ខ! <u>សច្ចធម៌ទី២-ទុក្ខសមុទយអរិយសច្ចៈ</u> ប្រែៈហេតុដែលឲ្យកើតទុក្ខមានពិតប្រាកដគឺតណ្ហា,តណ្ហាគឺសេចក្តីប្រាថ្នានេះដែលនាំឲ្យកើតទុក្ខ,បើសេចក្តីប្រាថ្នាមានច្រើនប៉ុណ្ណា?ទុក្ខក៏មានច្រើនប៉ុណ្ណោះដែរ។មនុស្សទាំងអស់នៅលើពិភពលោកទាំងមូលនេះ លុះណាតែធ្វើជាម្ចាស់លើខ្លួនឯងបានគឺគ្រប់គ្រងលើចិត្តរបស់ខ្លួនបាន,ជាម្ចាស់លើអ្វីៗទាំងអស់ទាល់តែលែងធ្វើជាទាសៈនៃតណ្ហា!ទើបលែងមានទុក្ខ,ព្រោះតណ្ហាគឺលោភៈទោសៈមោហៈទាំង៣នេះ វាជាអកុសលមូលជា មេ នាំឲ្យកើតទុក្ខ។ លោភៈ ការលោភលន់ចង់បានហួសប្រមាណ។ ទោសៈការខឹងប្រទុស្តបៀតបៀនគុំគួន។ មោហៈ សេចក្តីល្ងង់មិនដឹងការពិត,ចចេស!ធ្វើអ្វីៗច្រើនបំពានលើធម៌,លើច្បាប់,ធ្វើអ្វីៗ ជាអកុសលៗវានាំឲ្យមានសង្ខារ,បើមានសង្ខារហើយវាជួបប្រទះតែនឹង ទុក្ខំ អនិច្ចំ អនត្តា នេះតែដដែលៗហ្នឹង!ឥតមានផ្លូវណាអាចគេចវេះបានឡើយប្រសិនបើនៅតែក្រាស់ដោយតណ្ហានោះ។ព្រោះតណ្ហានេះឯងដែលនាំឲ្យសព្វសត្វវិលវល់កើតស្លាប់ៗនៅតែក្នុងវដ្តសង្សារហ្នឹង!ព្រះពុទ្ធដីកាថាៈ នត្ថិ តណ្ហាសមានទី គ្មានទឹកទន្លេ,ទឹកស្ទឹងណា!ហូរស្មើនឹងតណ្ហាគឺសេចក្តីប្រាថ្នារបស់មនុស្សលោកឡើយ,ហូរមិនចេះឈប់ឡើយ!។<u>សច្ចធម៌ទី៣-ទុក្ខនិរោធអរិយសច្ចៈ</u> ប្រែៈសេចក្តីរំលត់ទុក្ខមានពិតប្រាកដ!។ បណ្ឌិតជន

ពោលថាៈបើនរជនណារកឃើញហេតុដែលនាំឲ្យកើតទុក្ខហើយ! នរ-ជននោះក៏អាចរកឃើញការរំលត់ទុក្ខបានដែរ!គឺនិរោធឬវិមុត្តិប្រែៈការរួចស្រឡះ,រួចដ៏ល្អប្រសើរ,រួចផុតពីទុក្ខលែងធ្វើអំពើអាក្រក់គ្រប់យ៉ាង, លែងលង់ក្នុងកិលេសគ្រឿងសៅហ្មងចិត្តៈលោភៈទោសៈមោហៈទៀតហើយ! ជាការរួចជាន់ខ្ពស់, ការរំដោះខ្លួនថ្នាក់កំពូល, មានសេរីភាពដ៏បរិបូរណ៍, ជាទីស្ងប់, ជាត្រើយនាយ, ជាកន្លែងរលត់អស់ទៅនៃតណ្ហាគ្មានសេសសល់ឡើយគឺព្រះនិព្វាននោះឯង។<u>សច្ចៈធម៌ទី៤-ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈឬ</u> មគ្គអរិយសច្ចៈប្រែៈមាគ៌ា-ផ្លូវ,សម្រាប់ការប្រតិបត្តិដើម្បីឆ្ពោះទៅកាន់ការរំលត់ទុក្ខមានពិតប្រាកដ!។ផ្លូវដែលត្រូវប្រតិបត្តិដើម្បីទៅដល់ទីរំលត់ទុក្ខ,ព្រះពុទ្ធសម្តែងមានពិតប្រាកដ, ប៉ុន្តែរឿងទៅដល់ឬមិនដល់ ស្រេចនៅលើអ្នកដើរ-អ្នកប្រតិបត្តិ, បើប្រតិបត្តិឲ្យដល់កំរឹតទើបបានទៅដល់ បើប្រតិបត្តិមិនដល់កំរឹតទេ,មិនបានដល់ឡើយ បើ<u>ព្រះយោគាវចរ</u> ណាចង់ប្រតិបត្តិឲ្យបានដល់នូវនិរោធឬវិមុត្តិជាទីអស់ទៅនៃតណ្ហាទាំង៣យ៉ាងនោះ,ព្រះពុទ្ធទ្រង់ចង្អុលប្រាប់នូវវិធី៨ប្រការទៀតហៅថា"អដ្ឋង្គិកមគ្គ"ផ្លូវប្រកបដោយអង្គ៨គឺ១-សម្មាទិដ្ឋិការយល់ត្រូវ។២-សម្មាសង្កប្បៈការត្រិះរិះត្រូវ។ ៣-សម្មាវាចា សំដីត្រូវ ៤-សម្មាកម្មន្តៈការងារត្រូវ៥-សម្មាអាជីវៈការចិញ្ចឹមជីវិតត្រូវ,៦-សម្មាវាយាមៈ ព្យាយាមត្រូវ,៧-សម្មាសតិការរលឹកត្រូវ, ៨-សម្មាសមាធិ ការដំកល់ចិត្តឲ្យនឹងត្រូវ,ខ្ញុំនឹងអធិប្បាយពង្រីកសេចក្តីបន្តិចៗបន្ថែមទៀតថា ១-សម្មាទិដ្ឋិប្រែៈការយល់ត្រូវតើយល់យ៉ាងម៉េចដែលហៅថាយល់ត្រូវនោះ? ចម្លើយៈដែលហៅថាយល់ត្រូវនោះដូចជាយល់ថា"បើធ្វើអំពើល្អបានផលល្អ, បើធ្វើអំពើអាក្រក់! បានផលអាក្រក់,បើធ្វើបុណ្យ បានបុណ្យ,បើធ្វើបាប! បានបាប,ម៉ែ,ឪ-មានគុណ, ការយល់ដូច្នេះ ជាដើមដែលហៅថា"ការយល់ត្រូវ"នោះ។ ២-សម្មាសង្កប្បៈ ការត្រិះរិះត្រូវ,គឺត្រិះរិះពិចារណាឲ្យដូចជាការយល់ត្រូវអញ្ចឹងដែរ! ត្រិះរិះពិចារណាទៅ

តាមសច្ចៈ សុចរិត,យុត្តិធម៌,ជាអំពើល្អអញ្ចឹងជាដើមឡើងទៅ ហៅថា សម្មាសង្កប្បៈហើយ។៣-សម្មាវាចា សំដីត្រូវ,បើយើងយល់ត្រូវហើយ ត្រិះរិះពិចារណាត្រូវហើយ,យើងក៏និយាយឲ្យត្រូវឲ្យមានសច្ចៈសុចរិត យុត្តិធម៌តាមដែលយើងបានយល់ត្រូវនោះជាដើមទៅ,បែបនេះហៅថា សំដីត្រឹមត្រូវហើយ!។៤-សម្មាកម្មន្តោ ការងារត្រូវ,យើងធ្វើការងារអ្វីៗ ជារបររកស៊ីចិញ្ចឹមជីវិតក្តី យើងធ្វើទៅតាមតម្រាយផ្លូវ ដែលយើងបាន យល់ត្រូវរួចមកហើយនោះទៅគឺយើងធ្វើទៅតាមផ្លូវសច្ចៈសុចរិតយុត្តិ ធម៌,ជាការងារដែលប្រាសចាកទោស,គឺត្រូវធ្វើយ៉ាងណាឲ្យបានទ្រព្យ សម្បត្តិមកយើងផងហើយកុំឲ្យប៉ះពាល់សិទ្ធិឬខូចប្រយោជន៍របស់អ្នក អ្នកដទៃផងការងារយ៉ាងនេះហៅថាការងារត្រឹមត្រូវហើយ!។ ៥-សម្មា អាជីវោ ការចិញ្ចឹមជីវិតត្រូវ, គឺត្រូវចិញ្ចឹមជីវិតទៅតាមសម្មាអាជីវោទៅ តាមមានតាមបាន មានសេចក្តីសន្តោសប្រព្រឹត្តទៅតាម សច្ចៈសុចរិត យុត្តិធម៌មិនបៀតបៀនគេ,មិនកេងប្រវញ្ច័គេ, និងត្រូវរស់នៅតាមបែប មនុស្សមានមនុស្សធម៌ដ៏ល្អប្រសើរ នេះហើយដែល ហៅថាការចិញ្ចឹម ជីវិតត្រឹមត្រូវនោះ។ទី៦-សម្មាវាយាមោព្យាយាមត្រូវ,គឺព្យាយាមធ្វើអ្វីៗ តាមគន្លងធម៌តាមសច្ចៈ សុចរិត យុត្តិធម៌យើងធ្វើអ្វីៗ តាមដែលយើង បានយល់ត្រូវ,បានត្រិះរិះគិតពិចារណាត្រឹមត្រូវរួចមកហើយនោះ,នោះ ហើយដែលហៅថាព្យាយាមត្រូវ ។៧-សម្មាសតិការរលឹកត្រូវ, គឺរលឹក ទៅតាមស្មារតីសច្ចៈសុចរិតយុត្តិធម៌ ដែលមានសម្មាទិដ្ឋិខាងដើមនោះ ជាត្រីវិស័យ, រលឹកនូវសកម្មភាពដ៏ល្អប្រពៃគ្រប់យ៉ាងរបស់យើងដែល បានដំណើរការត្រឹមត្រូវមកហើយ, នោះហើយដែលហៅថាការរលឹក ត្រូវនោះ។ ៨-សម្មាសមាធិ ការដម្កល់ចិត្តឲ្យនឹងត្រូវ, គឺដម្កល់ចិត្តនៅ ក្នុងផ្លូវត្រូវ,ផ្លូវសច្ចៈសុចរិតយុត្តិធម៌ហ្នឹងឯង,ត្រូវដម្កល់ចិត្តឲ្យស្ថិតនៅ ក្នុងសីល.សមាធិ.បញ្ញា! ឬក៏អាចឈានទៅដល់ដម្កល់ក្នុង បីតិ.សុខៈ ឯកក្កតា ទៀតនោះរឹតតែប្រសើរ ។ អង្គមគ្គប្រការទី៨នេះ លំបាកកំ-

ណាត់ប្រតិបត្តិណាស់ ព្រោះចិត្តជានាមធម៌។ទាំង៨នេះជាផ្លូវប្រតិបត្តិ សម្រាប់ធ្វើដំណើរឆ្ពោះទៅឲ្យដល់វិមុត្តិគឺការរំលត់ទុក្ខនោះប៉ុន្តែដែល បានទៅដល់ឬមិនបានដល់នោះ ស្រេចនៅលើអ្នកដើរឬមិនដើរនោះ ឯង។សាធុសប្បុរសទាំងឡាយ!ប្រសិនបើមនុស្សនៅលើពិភពលោក នេះទាំងមូលទាំងអស់គ្នា ចេះពិចារណាឲ្យឃើញច្បាស់តាមសច្ចធម៌ ពិតទាំង៤ប្រការនេះព្រមទាំង អដ្ឋង្គិកមគ្គទាំង៨ប្រការថែមទៀតផង តែងមានចិត្តទន់-ស្ងប់, មានសេចក្តីប្រាថ្នាតិចខ្លះៗទៅដែរ! នឹងមាន សេចក្តីសន្តោស,ចេះស្រឡាញ់,ចេះអនុគ្រោះមនុស្សជាតិផងគ្នាយ៉ាង ពិតប្រាកដបាន, កិច្ចដ៏ប្រសើរបែបនេះ ជាគន្លងផ្លូវនៃអរិយបុគ្គល! ។ សាធុរ៉ា! ហៃសាធុសប្បុរសទាំងឡាយ!ព្រះធម៌ទេសនាដែលស្តីអំពី "ព្រះពុទ្ធសាសនា"!អស់លោកបានស្តាប់,បានយល់សព្វគ្រប់មកដែរ ហើយ, អស់លោកអ្នកគោរពប្រតិបត្តិបានយ៉ាងណា? ត្រឹមកំរឹតណា, តាមស្មារតី,សម្បជញ្ញៈរបស់ខ្លួនរៀងៗខ្លួនចុះ!តែសូមលោកអ្នកសប្បុ រសយល់ឲ្យច្បាស់តាមសច្ចៈធម៌ថាៈ ព្រះពុទ្ធសាសនាមិនបានបង្ខំ នូវ នរជនណា?ឬជនជាតិណា?សាសន៍ណាមួយ,ឲ្យធ្វើតាមឲ្យជឿតាម នោះទេ!, ព្រះពុទ្ធគ្រាន់តែជាអ្នកបង្ហាញប្រាប់ផ្លូវថាៈ ធ្វើយ៉ាងនេះបាន ផលយ៉ាងនេះ,ធ្វើយ៉ាងនោះ បានផលយ៉ាងនោះគឺប្រាប់អំពីហេតុផល ច្បាស់លាស់ថាបើនរជនណាធ្វើអំពើល្អតែងបានផលល្អ,បើនរជនណា ធ្វើអំពើអាក្រក់តែងបានផលអាក្រក់តែប៉ុណ្ណោះ!។ រួចបើមនុស្សណាកំ ពុងតែធ្វើអំពើអាក្រក់ក្នុងបច្ចុប្បន្ននេះហើយមិនបានឃើញផលអាក្រក់ ឃើញបានតែផលល្អៗគឺផលនៃអំពើល្អដែលមនុស្សនោះបានធ្វើពីអតី តជាតិមកនោះវាកំពុងតែឲ្យផលទេ,ម្លោះហើយផលអាក្រក់នៃអំពើអា-ក្រក់ដែលមនុស្សនោះកំពុងតែធ្វើក្នុងពេលបច្ចុប្បន្ននេះ វារកឱកាសឲ្យ ផលមិនទាន់បាន,ប៉ុន្តែសូមលោកអ្នកសប្បុរសយល់និងចាំឲ្យច្បាស់ថា គង់ថ្ងៃណាមួយឬពេលណាមួយឬក៏ជាតិណាមួយ, ផលអាក្រក់នៃអំពើ

អាក្រក់នោះ,នឹងផ្តល់ឲ្យដល់មនុស្សនោះមិនខានជាដាច់ខាតផលនោះ មិនបាត់ទៅណាទេប៉ុន្មានជាតិទៅមុខទៀតក៏ដោយក៏ផលអាក្រក់នោះ មិនភ្លេចមនុស្សអាក្រក់ហ្នុងទេ!សូមយល់ឲ្យច្បាស់អញ្ចឹង! គឺវាពិតជា អញ្ចឹង! ដូចមានព្រះពុទ្ធដីកា សំដែងច្បាស់ថាៈ មធុវា មញ្ញតី ពាលោ យាវ បាបំ ន បច្ចតិ យទា ច បច្ចតី បាបំ អថទុក្ខំ និគច្ឆតិ ពេលណា ដែលបាបមិនទាន់ឲ្យផល ពេលនោះមនុស្សពាលល្ងង់ខ្លៅសំគាល់ថា បាបមានរសជាតិផ្អែមដូចជាទឹកឃ្មុំ ប៉ុន្តែពេលណាដែលបាបវាឲ្យផល ពេលនោះ ទើបមនុស្សពាលល្ងង់ខ្លៅស្រក់ទឹកភ្នែកតែម្តង!!។ គឺវាពិត ជាអញ្ចឹង!។ព្រះធម៌ទេសនាស្តីអំពី“ព្រះពុទ្ធសាសនា” សូមបញ្ជាក់ឲ្យ ខ្លីសារជាថ្មីឡើងវិញ ឲ្យងាយចាំ, ងាយយល់ថាៈ ប្រសិនបើមានគេធ្វើ សំនួរៈទី១-បើគេសួរថាៈ តើហេតុអ្វីបានជាអ្នកកាន់ព្រះពុទ្ធសាសនា? ចម្លើយៈ ថាបានជាខ្ញុំកាន់ព្រះពុទ្ធសាសនាពីព្រោះព្រះពុទ្ធ ជា“មេ”នៃ ពុទ្ធសាសនាព្រះអង្គជាមនុស្សដូចខ្ញុំដែរ,តែព្រះអង្គជា អច្ឆរិយមនុស្ស ដ៏អស្ចារ្យប្លែកពីទេវតា,ឥន្ទ,ព្រហ្ម, ឆ្ងាយណាស់!ព្រះអង្គជាសព្វញ្ញុតា- ញាណ, មានញាណដ៏ជ្រាលជ្រៅបំផុតអាចជ្រាបដឹងរឿងពីអតីតៈរាប់ ក័ប្ប និងរឿងបច្ចុប្បន្នរហូតដល់រឿងទៅអនាគតវែងឆ្ងាយ តទៅទៀត ណាស់ឥតមានទីទើសទាក់សល់ចន្លោះឡើយ! ។ ទី២- បើគេសួរថាៈ តើព្រះពុទ្ធសាសនាមានអត្ថន័យដូចម្តេច?ចម្លើយៈមានអត្ថន័យថាជា ពាក្យប្រៀនប្រដៅរបស់ព្រះព្រះពុទ្ធ,ព្រះពុទ្ធដំបូន្មាននេះមានសច្ចភាព ណាស់!មានហេត-ផលច្បាស់លាស់ណាស់! ពាក្យរបស់ព្រះពុទ្ធរឿង អ្វីក៏ដោយ,បើព្រះអង្គពោលហើយមានតែមួយផ្លូវគត់ឥតមានពីរឡើយ គឺបើព្រះពុទ្ធពោលថាម៉េច,វាពិតជាអញ្ចុង!ឥតប្រែប្រួលឡើយ។ ទី៣- បើគេសួរៈតើព្រះពុទ្ធឬព្រះពុទ្ធសាសនាប្រដៅមនុស្សថាម៉េច?ចម្លើយ ពាក្យដែលព្រះពុទ្ធប្រដៅមនុស្សទូទៅនៅលើពិភពលោកនេះទាំងមូល ទាំងទេវតា,ឥន្ទ,ព្រហ្ម,ផងមានច្រើនណាស់! ប៉ុន្តែបើរួមឲ្យខ្លីហើយខ្លឹម

មកនៅត្រឹមតែ៣ព្រះឱស្ឋឬ៣ម៉ាត់ប៉ុណ្ណោះគឺៈទី១-ថាៈ កុំធ្វើអំពើបាប អាក្រក់គ្រប់យ៉ាងគ្រប់ៗគ្នា! បាលីៈ សព្វបាបស្ស អករណំ។ ទី២-ថាៈ គួរខំធ្វើអំពើល្អគឺបុណ្យឲ្យបានច្រើនគ្រប់ៗគ្នា!ៈកុសលស្សូបសម្បទា។ ទី៣-ថាៈត្រូវសំអាតចិត្តឲ្យល្អផូរផង់,ស្រឡាញ់រាប់អានមនុស្សដូចគ្នា! និងសព្វសត្វទូទៅផង ឲ្យបានល្អប្រសើរបំផុត! សចិត្តបរិយោទបនំ។ ទាំង៣នេះជាមូលដ្ឋានគ្រឹះនៃព្រះពុទ្ធសាសនា! ខ្ញុំឃើញពុទ្ធសាសនា មានឧត្តមគតិដ៏ល្អប្រសើរខ្ពង់ខ្ពស់យ៉ាងនេះ ទើបខ្ញុំកាន់ពុទ្ធសាសនា! នែ!ចម្លើយបើឆ្លើយឲ្យខ្លីបំផុត!ត្រឹមតែប៉ុណ្ណឹងទេ!។ ព្រះធម៌ស្ដីអំពីព្រះ ពុទ្ធសាសនាចប់ត្រឹមប៉ុណ្ណោះឯង ឯវំ ៕